# កម្ពុជា ព្រះរាជាណាចក្រ នៃ វប្បធម៌

## Cambodia Kingdom of Culture

### ទស្សនីយ៍ភាពសិល្បៈអរូបីយ៍នៃមនុស្សជាតិ

Performing Art of Intangible Heritage of Humanity






ក្នុងករណីពិសេសលោកអ្នក ឬក្រុមហ៊ុនទេសចរណ៍ដែលមានភ្ញៀវខុសពី
ថ្ងៃកំណត់សូមទំនាក់ទំនងមកឲ្យបានមួយសប្តាហ៍មុនយើងខ្ញុំនិងរៀបចំជូន ។ សូមអរគុណ!
លេខទូរស័ព្ទទំនាក់ទំនង: ០១១ ៩២ ០៥ ៩២ / ០៩២ ៧៤ ៧៣ ៧៣/ ០១២ ៥៥៦ ៤៨០
សូមទាក់ទង CATA សំរាប់ការបញ្ចុះតំលៃ : ០២៣ ២១២ ៤២១ / ០១២ ៣០៩ ៧០៧

For private show arrangement, please contact us one week in advence. Thank you!

Contact H/P : 011 920 592/ 092 747 373 /012 556 480

Please contact CATA for Discount : 023 212 421/012 309 707



សំដែងជូនរៀងរាល់ល្ងាចថ្ងៃសុក្រ ចាប់ពីថ្ងៃទី ១១-០៣-២០១១
វេលាម៉ោង ១៩.០០ នៅក្នុងបរិវេណសាលសន្និសិទ្ធចតុម្មុខ
ប្រកបដោយខ្យល់អាកាសដ៏សែនមនោរម្យ

Show Every Friday Evening at 19:00 in CHAK TOMUK CONFERENCE HALL From 11 March 2011

Please come and join us for a Pleasant Atmosphere !

យើងមានសេចក្តីរីករាយដែលលោកអ្នកបានមកទស្សនាសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា បង្ហាញពីវប្បធម៌ដ៏ចំណាស់ដែលជាមត៌កតាំងពីសម័យអង្គរត្រូវបានថែរក្សារហូតមកដល់បច្ចុប្បន្ន។ សិល្បករចូលរួមសំដែងចំនួន ៦០ ទៅ ៨០នាក់ ដែលមានកំរិតខ្នាតជាតិ ជាពិសេសបានសំដែងលើឆាកអន្តរជាតិទៀតផង។

We are very pleased to welcome you at our special art performing of the Kingdom of Cambodia, epitomizing an old civilization and legacy of the Angkor period, which has been preserved till the present. There are a total of 60-80 artists of national level, having performed on international stages, participate in the program.

## ការបង្ហាញអត្ថន័យក្បាច់ នៃក្បាច់របាំបុរាណខ្មែរ

## Demonstration of Dance Movements and Gestures Of the Khmer Classical Dance



## របាំប្រពៃណី ព្លយសួយ

ជាគ្រឿងផ្លុំធ្វើអំពីផ្លែឃ្លោកស្ងួតដែលមាននៅប្រើនិងថែរក្សាយ៉ាង ខ្ជាប់ខ្ជួនជាពិសេសក្នុងចំណោមបងប្អូនជនជាតិភាគតិច។ របាំព្លយសួយ មានដើមកំណើតនៅក្នុងខេត្តកំពង់ស្ពឺ ។

## Mouth Organ Of The Suoy Ethnic Dance



Ploy is a mouth organ type of instrument. A folk dance originating in the province of Kampong Speu, dancers blow into the ploy or mouth organs to recall the origin of time and to resort to the myth of the eternal return.

## របាំអប្សរា



អប្សរា ជាស្រីទេពអប្សរនិងស្រីវាំសួគ៌ មានប្រភពដើមពីការកូរសមុទ្រទឹកដោះរវាងទេវតានិងអសុរា ដើម្បីយកទឹកអម្រឹតដែលជាឱសថអមតៈ។ របាំអប្សរា ត្រូវបាន គេបង្កើតឡើងដោយយកតម្រាប់តាមកាយវិការនៃទេពអប្សរ ស្ថានសួគ៌ ដែលមានឆ្លាក់លំអនៅលើជញ្ជាំងនានានៃប្រាសាទអង្គរវត្តទាំងនោះ។ ខ្មែរយើងមានជំនឿថា: អប្សរាជាបុព្វនារីនិងជាមាតារបស់របាំខ្មែរ និងជានិមិត្តរូបនៃវប្បធម៌ខ្មែរផង។

## Apsara Dance

In Khmer mythology, all apsara were born from the foam surface of the ocean of milk, when tevoda (heavenly beings) and assura (demons) churned the ocean of milk with the gigantic naga in search for toeuk amrett or the elixir of immortality. The dance portrays mera, dressed in white for purity, dancing in her garden. She is joined by her handmaidens, also apsara, who produce flowers which express great love of the people and the country.

## របាំកណ្តូបសេះ

របាំកណ្តូបសេះ មានដើមកំណើតចេញមកពីខេត្តស្វាយរៀង កាយវិការភាគច្រើនធ្វើត្រាប់តាមសត្វកណ្តូបសេះក្នុងពេលសំដែងយើងប្រើត្រឡោកដូងមកចងភ្ជាប់ជាមួយដៃជើងរាំ។

## Kandob Ses Dance (Praying Mantis Dance)



This tradition dance originates from SvayRieng Province. The gestures of this dancelargely imitate the praying mantis (grasshopper)

## មណីមេខលា



របាំមណីមេខលាជារបាំបុរាណខ្មែរមួយ ស្តែងឡើងអោយឃើញពីការលោភៈ ទោសៈរបស់មនុស្សឃោរឃៅ មកលើមិត្តភក្តិ និង អ្នកស្លូតត្រង់ ហើយត្រូវ វិនាសជាចុងក្រោយ ។

## Moni Mekhala

Moni Mekhala is a classical Khmer dance which depicts the greed and anger of a cruel person towards the innocent. The wicked must be vanquished in the end.

## របាំក្ងោកប៉ៃលិន

របាំក្ងោកប៉ៃលិនមានដើមកំណើតពីជនជាតិភាគតិច (កុឡា) ដែលរស់នៅក្នុងតំបន់ប៉ៃលិនទិសបច្ចឹមប្រទេស ។ របាំនេះគឺជារឿងព្រេងនិទានរបស់អ្នកស្រុកប៉ៃលិនម្នាក់ដែលបានទូលថ្វាយព្រះមហាក្សត្រអំពីភាពដ៏អស្ចារ្យនៃសត្វក្ងោក ។

## Peacock Of Pailin Dance



This traditional dance comes frome the Kola ethnic group, who live in the region of Pailin in the west of Cambodia. the dance relates to a Pailinian legend a bout a magic peacock who goes to preach to the king.

## របាំទេពមនោរម្យ



ទេព = ទេវតា + មនោរម្យ: រីកចំរើនសុភមង្គល។ ពួកទេវតា រាំរបាំនេះសំរាប់បួងសួង សុំភាពសម្បូររុងរឿង ជូនដល់ប្រជាពលរដ្ឋ និង ប្រទេសជាតិខ្មែរ ។ របាំទេពមនោរម្យនេះ ជារបាំបុរាណមួយក្នុងកម្រងរបាំព្រះរាជទ្រព្យ ដែលទាក់ទងនិងជំនឿ របស់ប្រជាពលរដ្ឋ ដូចជា សុំទឹកភ្លៀងគ្រប់គ្រាន់ សំរាប់ផលដំណាំ ឬ សុំអោយបាន ជាសះស្បើយពីរោគាព្យាធិទាំងឡាយ។

## Tep Monorom

Tep Monorom is a pure dance piece in the classical style. The dancers represent tevoda (divine beings) who dance for the happiness and prosperity of the people.

## របាំភោគផល





ជនជាតិភាគតិចព្នងក្នុងខេត្តរតនគិរីនិងមណ្ឌលគិរីសំដែងរបាំភោគផលដែលបង្ហាញពី ការជ្រើសរើសរកដីដើម្បីដាំដំណាំ។ របាំនេះបង្ហាញផងដែរនូវផលិតផលដ៏ប្រសើររបស់គេតាមរយៈក្បាច់និងកាយវិការរបស់របាំ។

## Good Crops Dance

Like many countries in the world, Cambodia is home to ethnic groups. Although they bear differnces, their traditions, customs,. beliefs, and lifestyles are absolutely respected. As living proof of this respect, ethnic minority dances and music are researched, collected, studied, and included in the Khmer artistic repertoires.